# អនុក្រឹត្យ
# ស្ដីពី
# ការពិន័យអន្តរការណ៍ចំពោះ
# បទល្មើសនឹងច្បាប់ ស្ដីពី ជលផល

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៩១ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានរដ្ឋបាល
ប៉ុស្តិ៍
លេខ: ......
ថ្ងៃទី: ......
បញ្ជូន: ......

# អនុក្រឹត្យ

## ស្តីពី

ខុទ្ទកាល័យ
ប៉ុស្តិ៍
លេខ: ......
ថ្ងៃទី: ......
បញ្ជូន: ......

## ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីជលផល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៥/០២៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីបទល្មើសនិងចំនួនទឹកប្រាក់ដែលត្រូវពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីជលផល ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបទល្មើសនឹងច្បាប់ស្តីពីជលផល ដែលត្រូវពិន័យអន្តរការណ៍។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម** សំដៅដល់ការដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើវារីវប្បកម្មឬការធ្វើនេសាទ ក្នុងគោលបំណងសម្រាប់ទិញ លក់ ឬចែកចាយបន្តក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី៥០០(ប្រាំរយ)គីឡូក្រាម ឬការនាំចេញ នាំចូល ឬនាំឆ្លងកាត់លើសពី៥០(ហាសិប)គីឡូក្រាម

- **ការនេសាទសម្រាប់ធ្វើការពិសោធនិងការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល** សំដៅដល់ការនេសាទក្នុងគោលបំណងប្រមូលទិន្នន័យវិទ្យាសាស្ត្រជលផល ដែលមិនសម្រាប់ធ្វើការទិញ លក់ ចែកចាយ ឬប្រើប្រាស់ក្នុងជីវភាពរស់នៅ

- **វត្ថុចាប់យក** សំដៅដល់វត្ថុតាងឬវត្ថុដទៃទៀតដែលត្រូវបានចាប់យក ឬឃាត់ទុក ឬបង្កកនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ

- **ឧបករណ៍នេសាទស្បៃមុង** សំដៅដល់ឧបករណ៍នេសាទដែលមានក្រឡាតូចជាង៥(ប្រាំ)មិល្លីម៉ែត្រ

- **សម្រាស់** សំដៅដល់ជម្រកសិប្បនិម្មិតជាប់បាតទឹក បង្កើតដោយការប្រើជាអាទិ៍មែកឈើ ដើមឈើ គល់ឈើ ឬស្សី លូបេតុង សម្បកកង់រថយន្ត។ ជម្រកសិប្បនិម្មិត ជាអាទិ៍កក់ ព្រលឹត លំចង់ កំប្លោក ត្រកួន កំពីងពួយ យាប្លង ក្រចាប់ សារាយ ចក ត្រូវចាត់ទុកដូចជាកន្សំ

- **ការដាក់សម្រាស់** សំដៅដល់សកម្មភាពនេសាទដោយយកអួន មង ឬព្រួល ទៅហ៊ុមសម្រាស់ ដើម្បីក្រសោបចាប់ត្រីឬវារីសត្វ

- **តំបន់បឹងទន្លេសាប** សំដៅដល់តំបន់គ្រប់គ្រងជលផលដែលស្ថិតនៅក្នុងបឹងទន្លេសាប រួមមានបឹងតូច និងបឹងធំ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ

- **តំបន់ក្រៅបឹងទន្លេសាប** សំដៅដល់តំបន់គ្រប់គ្រងជលផលដែលស្ថិតនៅក្រៅបឹងទន្លេសាប រួមមានតំបន់ជុំវិញបឹងទន្លេសាប តំបន់ទន្លេមេគង្គ តំបន់ទន្លេសាប តំបន់ទន្លេបាសាក់ និងទំនាបលិចទឹកផ្សេងទៀតក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប

- **របៀបនេសាទបែបថ្មី** សំដៅដល់ការប្រើឧបករណ៍នេសាទដែលមានចែងក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល ដោយច្នៃប្រឌិតឱ្យនេសាទបានផលកាន់តែច្រើន។

## ជំពូកទី២

## អំពើល្មើសនិងចំនួនប្រាក់ដែលត្រូវពិន័យអន្តរការណ៍

**មាត្រា៤ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២០០ ០០០(ពីររយពាន់)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយមងបោះ មងកាំង ឬមងពស់ថ្លាន់។

២- ធ្វើការនេសាទដោយមងបណ្តែតឬមងពាក់ក្នុងកន្លែងការពារសត្វផ្សោតទន្លេមេគង្គ ដោយខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

៣- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប ដោយមុជចាក់ឬមុជបាញ់ត្រីនៅក្នុងអន្លង់។

៤- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយច្បូក ដោយខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

៥- ធ្វើការនេសាទដោយសន្ទូចរនងក្នុងកន្លែងការពារសត្វផ្សោតទន្លេមេគង្គ ដោយខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

៦- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយឈ្នាងអូសឬរុញខ្ទៅឬលៀសមិនប្រើម៉ាស៊ីនរួមផ្សំ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

៧- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយឈ្នក់ឬឆ្នុកប្រើភ្លើងរួមផ្សំ ឬមិនប្រើភ្លើងរួមផ្សំ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

៨- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយលប លបណាប៉ាវ ឬលូ ឬឡុក រួមផ្សំរបាំងព្រួល ឬបាំងសាច់អួន នៅតំបន់បឹងទន្លេសាបឬតំបន់ក្រៅបឹងទន្លេសាប ដែលមានប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយចន្លោះពីត្រៀមមួយទៅត្រៀមមួយឬក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតតូច នៃច្បាប់ស្តីពីជលផល។

៩- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយមងបណ្តែតឬមងពាក់ ក្នុងរដូវបិទនេសាទ ប្រវែងខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

១០- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយមងបណ្តែតឬមងពាក់ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល លើកលែងតែមងត្រីបណ្តូលល្ពៅ ត្រីចង្វាពោត ឬត្រីជន្លួញមាន់។

១១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយមងក្រឡុកឬមងហ៊ុម មងអូសដៃ ឬអួនអូសដៃ ដោយក្រឡាឬប្រវែងខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

១២- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយចៃរ៉ាមិនប្រើម៉ាស៊ីនឬខ្យល់រួមផ្សំ ឬជនមិនប្រើម៉ាស៊ីនរួមផ្សំ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

១៣-ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ដោយមុជចាក់ឬមុជបាញ់ត្រីក្នុងតំបន់ផ្កាថ្ម តំបន់ថ្មប៉ប្រះទឹក។

១៤- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយនាស់ឬឈ្នាងអូសគ្រែងឈាមប្រើដោយដៃ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

១៥- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយមង អួនហ៊ុមកៀនច្រាំង អួនត្រីស អួនខូវ ឬមងខូវ អួនកេវឬមងកេវ ឬអួនត្រីកាឡេងតេង ប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតតូច នៃច្បាប់ស្តីពីជលផល។

១៦- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយលបមឹក លបក្តាម លបបង្គា លបខ្យង លបត្រី លបត្រីគុកកែ ឬលបប្រើសច្រើនឬលបកន្ទុយកណ្តុរ ចំនួនស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតតូច នៃច្បាប់ស្តីពីជលផល។

១៧- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយលបប្រមផ្សំរបាំងព្រួល ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល។

១៨- ធ្វើការនេសាទខ្នាតតូចក្នុងកន្លែងសហគមន៍នេសាទ ដោយបុគ្គលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ឬគ្មានការអនុញ្ញាតពីសហគមន៍។

១៩- ធ្វើការនេសាទខ្នាតតូចក្នុងកន្លែងសហគមន៍នេសាទ ដោយមិនអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទ។

២០- ធ្វើនាវាចរណ៍ឆ្លងកាត់កន្លែងអភិរក្សជលផល ដោយរៀបចំឧបករណ៍នេសាទដែលមានលក្ខណៈប៉ុនប៉ងធ្វើការនេសាទឬសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់ធនធានជលផល។

២១- ធ្វើនាវាចរណ៍ឆ្លងកាត់ដែលមានឧបករណ៍ប៉ុនប៉ងធ្វើការនេសាទក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

២២- ធ្វើនាវាចរណ៍ដែលមានល្បឿនលើសពី៣០(សាមសិប)គីឡូម៉ែត្រក្នុងមួយម៉ោង ក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

២៣- ដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោម១ ០០០ (មួយពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច១៨ ចំណុច១៩ ចំណុច២០ ចំណុច២១ ចំណុច២២ និងចំណុច២៣ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច២ ចំណុច៣ ចំណុច៤ ចំណុច៥ ចំណុច៦ ចំណុច៧ ចំណុច៨ ចំណុច៩ ចំណុច១០ ចំណុច១១ ចំណុច១២ ចំណុច១៣ ចំណុច១៤ ចំណុច១៥ ចំណុច១៦ និងចំណុច១៧ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា៥ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥០០ ០០០(ប្រាំរយពាន់)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយមង៣(បី)ជាន់គ្រប់ប្រភេទ។

២- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដែលរាំងស្ទះផ្លូវនាវាចរណ៍ឬធ្វើការនេសាទ រួមផ្សំរបាំងព្រួលឬរបាំងសាច់អួនលាតសន្ធឹងលើសពី២/៣(ពីរភាគបី)នៃទទឹងមុខទឹកអូរ ព្រែក ឬស្ទឹង។

៣- ធ្វើការនេសាទដោយប្រើឧបករណ៍នេសាទស្បៃមុងប្រវែងខ្លីជាង១០០ម៉ែត្រ។

៤- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយម៉ាញ់ នាម ចៃរ៉ា ឬជន ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៥- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយអួនហ៊ុមឬអួនព្រយុង ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៦- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយឈ្នាងអូសឬរុញខ្ទៅឬលៀស ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៧- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយលប លបណប្រាំរ ឬលូ ឬឡុក រួមផ្សំរបាំងព្រួល ឬរបាំងសាច់អួន ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៨- ធ្វើការនេសាទលាតសន្ទឹងកាត់ព្រែកឬស្ទឹងនៃកន្លែងនេសាទតាមឆ្នេរ លើសពី១/២(មួយភាគពីរ) នៃប្រវែងទទឹងព្រែកឬស្ទឹងនៅពេលទឹកនាច ឬមិនបានរុះរើឧបករណ៍នេសាទចេញឱ្យអស់មុនថ្ងៃផុតកំណត់នៃលិខិតអនុញ្ញាត។

៩- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយឈិបយន្ត ឈ្នាងអូសគ្រែង គ្រំ ឬលៀស ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១០- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនត្រីស អួនត្រីកាឡេងតេង អួនហ៊ុមកៀនច្រាំង អួនខូវឬមងខូវ ឬអួនកេរឬមងកេរ ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយសន្ទូចរនង រនងធ្លាក់មឹក មង លបមឹក លបក្តាម លបបង្គា លបខ្យង លបត្រី ឬលបប្រើសច្រើនឬលបកន្ទុយកណ្តុរ ខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១២- ប្រើនាវាខ្នាតមធ្យមមិនបំពាក់និងរក្សាឧបករណ៍តាមដាននាវាឱ្យមានដំណើរការជាប្រចាំក្នុងការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ឬមិនអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការបំពាក់និងដំណើរការឧបករណ៍តាមដាននាវាឬនាវាពាក់ព័ន្ធនឹងការនេសាទ។

១៣- ធ្វើការនេសាទខ្នាតមធ្យមក្នុងកន្លែងសហគមន៍នេសាទ ដោយបុគ្គលដែលជាសមាជិកសហគមន៍នេសាទមិនអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់កន្លែងសហគមន៍នេសាទ។

១៤- ធ្វើការនេសាទខ្នាតមធ្យមក្នុងកន្លែងសហគមន៍នេសាទ ដោយបុគ្គលដែលមិនមែនជាសមាជិកសហគមន៍នេសាទឬគ្មានការអនុញ្ញាតពីសហគមន៍នេសាទ។

១៥- ដាក់សម្រាស់សម្រាប់ទាក់ទាញត្រីឬវារីសត្វក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបតិចជាង១០០(មួយរយ) ម៉ែត្រក្រឡា។

១៦- តាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាង២(ពីរ)គីឡូម៉ែត្រពីព្រំប្រទល់កន្លែងអភិរក្សជលផល។

១៧- តាំងទីលំនៅថ្មីក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

១៨- ធ្វើវារីវប្បកម្មក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

១៩- បន្សល់ទុកនូវដើមហេតុដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកឬព្រៃកោងកាង។

២០- លែងវារីសត្វគ្រប់ប្រភេទដែលមិនមែនជាពូជក្នុងប្រទេស ចូលទៅក្នុងតំបន់គ្រប់គ្រងជលផល ដោយគ្មានការអនុញ្ញាត។

២១- ដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពី១ ០០០ (មួយពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២២-នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល លើសពី៥០(ហាសិប)គីឡូក្រាម ដល់៥០០(ប្រាំរយ)គីឡូក្រាម។

វត្ថុចាប់យកក្នុងចំណុច១០ ចំណុច១១ ចំណុច១២ ចំណុច១៣ ចំណុច១៤ ចំណុច១៦ ចំណុច១៧ ចំណុច១៨ ចំណុច២១ និងចំណុច២២ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ ចំណុច៣ ចំណុច៤ ចំណុច៥ ចំណុច៦ ចំណុច៧ ចំណុច៨ ចំណុច៩ ចំណុច១៥ ចំណុច១៩ និងចំណុច២០ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា៦ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១ ០០០ ០០០(មួយលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោមៈ

១- ធ្វើការនេសាទសម្រាប់ធ្វើការពិសោធនិងការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលក្នុងតំបន់គ្រប់គ្រងជលផល ដោយគ្មានការអនុញ្ញាត។

២- ធ្វើការនេសាទខ្នាតតូចក្នុងកន្លែងអភិរក្សជលផលឬកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

៣- ធ្វើសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់សត្វផ្សោតក្នុងកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ។

៤- ធ្វើការនេសាទរួមផ្សំបំពង់ខ្យល់ឬម៉ាស៊ីនខ្យល់។

៥- ធ្វើការនេសាទដោយប្រើឧបករណ៍នេសាទស្នៀមុងប្រវែងពី១០០(មួយរយ)ម៉ែត្រ ដល់៣០០(បីរយ)ម៉ែត្រ។

៦- ធ្វើការនេសាទខ្នាតមធ្យមក្នុងរដូវបិទនេសាទនៃតំបន់គ្រប់គ្រងជលផលទឹកសាប។

៧- ធ្វើការនេសាទដោយមងដែលមានក្រឡាធំជាង១៥(ដប់ប្រាំ)សង់ទីម៉ែត្រក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប។

៨- ធ្វើការនេសាទដែលនាំឱ្យរាំងស្ទះចរាចរណ៍ត្រីនៅតំបន់បឹងទន្លេសាប ឬប្រើខ្សែចងគ្រប់ប្រភេទឱ្យមានរំញ័រ ឬមធ្យោបាយផ្សេងទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។

៩- ធ្វើការនេសាទដោយឈិបយន្តទឹកសាប។

១០- ដាក់សម្រាស់សម្រាប់ទាក់ទាញត្រីឬវារីសត្វក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបចាប់ពី១០០(មួយរយ)ម៉ែត្រក្រឡា ដល់៥០០(ប្រាំរយ)ម៉ែត្រក្រឡា។

១១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយម៉ាញ់ នាម ចៃវ៉ា ឬជន ប្រើកម្លាំងម៉ាស៊ីនស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១២- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយម៉ាញ់ នាម ចៃវ៉ា ឬជន ដោយប្រើកម្លាំងម៉ាស៊ីនខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៣- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយអួនហ៊ុមឬអួនព្រយុង ដោយក្រឡាឬប្រវែងខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៤- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយអួនហ៊ុមឬអួនព្រយុង ដោយប្រើកម្លាំងម៉ាស៊ីនខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៥- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយឈ្នាងអូសឬរុញខ្ទៅឬលៀស ដោយប្រើកម្លាំងម៉ាស៊ីនស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៦- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយឈ្នាងអូសឬរុញខ្ទៅឬលៀស ដោយប្រើកម្លាំងម៉ាស៊ីនខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៧- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយលប លបណប្ញរ៉ាវ លូ ឬឡុក រួមផ្សំរបាំងព្រួល ឬរបាំងសាច់អួន នៅតំបន់បឹងទន្លេសាបឬតំបន់ក្រៅបឹងទន្លេសាប ដែលមានប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយចន្លោះពីត្រៀមមួយទៅត្រៀមមួយឬក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៨- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយលប លបណប្ញរ៉ាវ លូ ឬឡុក រួមផ្សំរបាំងព្រួល ឬរបាំងសាច់អួន នៅតំបន់បឹងទន្លេសាបឬតំបន់ក្រៅបឹងទន្លេសាប ប្រវែងលើសការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទទឹកសាបខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

១៩- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយឈិបយន្ត ឈ្នាងអូសគ្រែង គ្រំ ឬលៀស ឬឈ្នាងអូសគ្រំក្រឡាហូល ដោយខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

២០- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយមង អួនហ៊ុមកៀនច្រាំង អួនត្រីស អួនខូវ ឬមងខូវ អួនកេវឬមងកេវ ឬអួនត្រីកាឡេងតេង ប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

២១- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយលបមឹក លបក្តាម លបបង្គា លបខ្យង លបត្រី លបត្រីតុកកែ ឬលបប្រើសច្រើនឬលបកន្ទុយកណ្តុរ ចំនួនស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

២២- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនអូសខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២៣-ធ្វើការនេសាទដែលរាំងស្ទះផ្លូវនាវាចរណ៍ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ។

២៤- ប្រើនាវាខ្នាតធំមិនបំពាក់និងរក្សាឧបករណ៍តាមដាននាវា ឱ្យមានដំណើរការជាប្រចាំក្នុងការធ្វើនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ឬមិនអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការបំពាក់និងដំណើរការឧបករណ៍តាមដាននាវាឬនាវាពាក់ព័ន្ធនឹងការនេសាទ។

២៥- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឈិបយន្តទឹកសាបឬឧបករណ៍នេសាទស្នៃមុង។

២៦- ផលិត ទិញ លក់ឧបករណ៍នេសាទខ្នាតធំស្របច្បាប់ជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាត ពីអង្គភាពជំនាញទទួលបន្ទុកជលផល។

២៧-ឡើងផល ផលិតផលជលផលដោយប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមឬខ្នាតធំ ដោយខុសពីកំពង់ផែឬកន្លែងឡើងផល ផលិតផលជលផលដែលបានកំណត់។

២៨- ធ្វើវារីវប្បកម្មខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬមិនគោរពតាមបទបញ្ជាបច្ចេកទេសឬលក្ខខណ្ឌតម្រូវ។

២៩- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រំ កូនលៀស កូនខ្យង កូនខ្ទៅ ឬកូន ឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ តិចជាង១០០(មួយរយ)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌ ក្នុងលិខិតអនុញ្ញាត។

៣០- ធ្វើអាជីវកម្មផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌ ក្នុងលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលតិចជាង៥០០(ប្រាំរយ)គីឡូក្រាម។

៣១- ដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៣២- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥០(ហាសិប)គីឡូក្រាម ដល់៥០០(ប្រាំរយ)គីឡូក្រាម។

៣៣- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម លើសពី៥០(ហាសិប)គីឡូក្រាម ដល់៥០០(ប្រាំរយ)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ចំពោះផល ផលិតផលជលផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។

៣៤- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់)គីឡូក្រាម។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច៣ ចំណុច៦ ចំណុច៨ ចំណុច១២ ចំណុច១៤ ចំណុច១៦ ចំណុច២២ ចំណុច២៤ ចំណុច២៦ ចំណុច២៧ ចំណុច២៨ ចំណុច៣០ ចំណុច៣១ ចំណុច៣២ ចំណុច៣៣ និងចំណុច៣៤ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច២ ចំណុច៤ ចំណុច៥ ចំណុច៧ ចំណុច៩ ចំណុច១០ ចំណុច១១ ចំណុច១៣ ចំណុច១៥ ចំណុច១៧ ចំណុច១៨ ចំណុច១៩ ចំណុច២០ ចំណុច២១ ចំណុច២៣ និងចំណុច២៥ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច២៩នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា៧ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទដោយប្រើឧបករណ៍នេសាទស្បៃមុងប្រវែងលើសពី៣០០(បីរយ)ម៉ែត្រ។

២- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបដោយប្រើភ្លើងរួមផ្សំឬមធ្យោបាយផ្សេងទៀតសម្រាប់ទាក់ទាញត្រីឬវារីសត្វផ្សេងទៀត។

៣- ដាក់សម្រាស់សម្រាប់ទាក់ទាញត្រីឬវារីសត្វ ក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបលើសពី៥០០(ប្រាំរយ)ម៉ែត្រក្រឡា ដល់១០០០(មួយពាន់)ម៉ែត្រក្រឡា។

៤- ទិញ លក់ ឬធ្វើសន្និធិពពួកសម្បកខ្យង ខ្ចៅ ឬគ្រំតាំងលម្ព ដែលជាប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៥- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រំ កូនលៀស កូនខ្យង កូនខ្ចៅ ឬកូនឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ ចាប់ពី១០០(មួយរយ)គីឡូក្រាម ដល់៥០០(ប្រាំរយ)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៦- ធ្វើអាជីវកម្មផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលចាប់ពី៥០០(ប្រាំរយ)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម។

៧- ធ្វើអាជីវកម្មផល ផលិតផលជលផលតិចជាង៥០០(ប្រាំរយ)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៨- ប្រើកូនត្រីឬកូនវារីសត្វផ្សេងទៀតដែលបានពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ដើម្បីផលិតជាម្សៅត្រី ខ្លាញ់ត្រី ឬចំណីវារីសត្វ ក្នុងការធ្វើវារីវប្បកម្មតិចជាង៥០០(ប្រាំរយ)គីឡូក្រាម។

៩- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី៥០(ហាសិប)គីឡូក្រាម ដល់៥០០(ប្រាំរយ)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១០- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់)គីឡូក្រាម។

១១- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ចំពោះផល ផលិតផលជលផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។

១២- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម។

វត្ថុចាប់យកក្នុងចំណុច៤ ចំណុច៦ ចំណុច៧ ចំណុច៨ ចំណុច៩ ចំណុច១០ ចំណុច១១ និងចំណុច១២ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ និងចំណុច៣ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច៥នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា៨ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទដោយអួនអូសទឹកសាប។

២- ធ្វើការនេសាទខ្នាតធំនៅក្នុងតំបន់គ្រប់គ្រងជលផលទឹកសាប ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌក្នុងសៀវភៅបន្ទុក ឬខុសទីតាំងដែលបានកំណត់។

៣- ដាក់សម្រាស់សម្រាប់ទាក់ទាញត្រីឬវារីសត្វក្នុងតំបន់គ្រប់គ្រងជលផលទឹកសាបលើសពី១ ០០០(មួយពាន់)ម៉ែត្រក្រឡា។

៤- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ដោយប្រើអួនទិត អួនហ៊ុមរួមផ្សំភ្លើង ឬអួនកាកឹមខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៥- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ដោយប្រើអួនអូសខ្នាតធំ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៦- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនទិត អួនកាកឹម ឬអួនហ៊ុមរួមផ្សំភ្លើង ប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតមធ្យម នៃច្បាប់ស្តីពីជលផល។

៧- ធ្វើការនេសាទឬធ្វើសកម្មភាពផ្សេងទៀតក្នុងតំបន់ស្មៅសមុទ្រឬផ្កាថ្ម ដែលប៉ះពាល់ដល់ការលូតលាស់នៃស្មៅសមុទ្រឬផ្កាថ្ម។

៨- ធ្វើការនេសាទដោយប្រើឧបករណ៍អួនអូសសេះសមុទ្រ។

៩- ធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១០- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យម មិនរក្សាទុកលិខិតអនុញ្ញាតច្បាប់ដើមឬច្បាប់ថតចម្លងផ្លូវការនៅក្នុងនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ និងមិនបង្ហាញដល់មន្ត្រីជលផលមានសមត្ថកិច្ចតាមការស្នើសុំ។

១១- ចូលសំចតនាវាដោយបោះយុថ្កាក្នុងតំបន់ផ្កាថ្ម ដោយគ្មានការអនុញ្ញាត។

១២- ប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាឬក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ដោយមិនមានស្លាកសញ្ញាសម្គាល់ឬអត្តសញ្ញាណនាវា ឬមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការដាក់ស្លាកសញ្ញាសម្គាល់នាវា។

១៣- ប្រើនាវាខ្នាតមធ្យមឬខ្នាតធំមិនបំពាក់និងរក្សាឧបករណ៍តាមដាននាវា ឱ្យមានដំណើរការជាប្រចាំក្នុងការធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់ក្រៅដែនយុត្តាធិការជាតិ ឬមិនអនុវត្តតាមលក្ខខណ្ឌតម្រូវក្នុងការបំពាក់និងដំណើរការឧបករណ៍តាមដាននាវាឬនាវាពាក់ព័ន្ធនឹងការនេសាទ។

១៤- ប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាដោយមិនមានស្លាកសញ្ញាសម្គាល់អត្តសញ្ញាណឧបករណ៍នេសាទ។

១៥- ធ្វើវារីវប្បកម្មខ្នាតធំ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬមិនគោរពតាមបទបញ្ជាបច្ចេកទេសឬលក្ខខណ្ឌតម្រូវ។

១៦- ធ្វើវារីវប្បកម្មវារីជាតដែលជាប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ ដោយគ្មានលិខិតអនុញ្ញាត។

១៧- ធ្វើវារីវប្បកម្មប្រភេទវារីជាតហាមឃាត់។

១៨- ប្រើកូនត្រីឬកូនវារីសត្វផ្សេងទៀតដែលបានពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ដើម្បីផលិតជាម្សៅត្រី ខ្លាញ់ត្រី ឬចំណីវារីសត្វក្នុងការធ្វើវារីវប្បកម្មចាប់ពី៥០០(ប្រាំរយ)គីឡូក្រាម ដល់១ ០០០(មួយពាន់)គីឡូក្រាម។

១៩- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រំ កូនលៀស កូនខ្យង កូនខ្ចៅ ឬកូន ឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ លើសពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២០- ប្រមូល ដកហូត ទិញ លក់ ធ្វើសន្និធិ ដឹកជញ្ជូនផ្កាថ្ម ដោយគ្មានការអនុញ្ញាត។

២១- ផលិត ទិញ លក់ ដឹកជញ្ជូនអួនអូសទឹកសាប។

២២- ប្រមូល ធ្វើសន្និធិ ឬដឹកជញ្ជូនឈើ អុស ធ្យូង ប្រភេទឈើព្រៃលិចទឹកឬព្រៃកោងកាង ជាលក្ខណៈអាជីវកម្ម។

២៣- ប្រើឈើព្រៃលិចទឹកឬព្រៃកោងកាងជាវត្ថុធាតុដើមសម្រាប់ជាថាមពលក្នុងរោងសិប្បកម្ម រោងចក្រ ឬមូលដ្ឋានកែច្នៃ។

២៤- ធ្វើអាជីវកម្មផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម។

២៥- ធ្វើអាជីវកម្មផល ផលិតផលជលផលចាប់ពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់) គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២៦- ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលតិចជាង៥០០(ប្រាំរយ)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២៧- ដឹកជញ្ជូន ទិញ លក់ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ដែលបានពីវារីវប្បកម្ម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២៨- ធ្វើពាណិជ្ជកម្មនាំចូល នាំចេញប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ដែលបានមកពីការធ្វើវារីវប្បកម្ម ដោយមិនអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផលឬមិនអនុលោមតាមអនុសញ្ញាសាយតេស ចំពោះប្រភេទដែលមានក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស។

២៩- នាំចូល នាំចេញ និងនាំឆ្លងកាត់ពូជវារីជាត ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៣០- នាំចូលនិងនាំឆ្លងកាត់ពូជវារីជាត ដោយគ្មានវិញ្ញាបនបត្រសុខភាព។

៣១- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម។

៣២- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី៥០០(ប្រាំរយ)គីឡូក្រាម ដល់ ២ ០០០(ពីរពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៣៣- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥ ០០០(ប្រាំពាន់) គីឡូក្រាម។

៣៤- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី២ ០០០(ពីរពាន់) គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ចំពោះផល ផលិតផលជលផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។

វត្ថុចាប់យកក្នុងចំណុច២ ចំណុច៤ ចំណុច៥ ចំណុច៦ ចំណុច៧ ចំណុច៩ ចំណុច១០ ចំណុច១១ ចំណុច១២ ចំណុច១៣ ចំណុច១៤ ចំណុច១៥ ចំណុច១៨ ចំណុច២០ ចំណុច២២ ចំណុច២៣ ចំណុច២៤ ចំណុច២៥ ចំណុច២៦ ចំណុច២៧ ចំណុច២៨ ចំណុច២៩ ចំណុច៣០ ចំណុច៣១ ចំណុច៣២ ចំណុច៣៣

និងចំណុច៣៤ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច៣ ចំណុច៨ ចំណុច១៧ និងចំណុច២១ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១៦និងចំណុច១៩នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា៩ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទខ្នាតមធ្យមក្នុងកន្លែងការពារសត្វផ្សោតទន្លេមេគង្គ។

២- ធ្វើការនេសាទខ្នាតធំក្នុងរដូវបិទនេសាទនៃតំបន់គ្រប់គ្រងជលផលទឹកសាប។

៣- ធ្វើការនេសាទខ្នាតធំក្នុងកន្លែងនេសាទសាធារណៈនៃតំបន់គ្រប់គ្រងជលផលទឹកសាប។

៤- ធ្វើការនេសាទដោយទំនប់រួមផ្សំនឹងឧបករណ៍នេសាទដែលធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល។

៥- ធ្វើការនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនទិត អួនហ៊ុមរួមផ្សំភ្លើង ឬអួនកាកឹម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៦- ធ្វើសកម្មភាពពាក់ព័ន្ធនឹងការនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៧- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យម មិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការធ្វើរបាយការណ៍អំពីផលនេសាទ ឧបករណ៍នេសាទ ទីតាំងនាវា តំបន់ធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

៨- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យម មិនរាយការណ៍អំពីទីតាំងប្រតិបត្តិការនៃការធ្វើនេសាទ ទិញ និងលក់ផលនេសាទ។

៩- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតធំ មិនរក្សាទុកលិខិតអនុញ្ញាតច្បាប់ដើមឬច្បាប់ថតចម្លងផ្លូវការនៅក្នុងនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទ និងមិនបង្ហាញដល់មន្ត្រីជលផលមានសមត្ថកិច្ចតាមការស្នើសុំ។

១០- នាំចូលនាវាខ្នាតមធ្យមសម្រាប់ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ដោយគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១១- ប្រើនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទដែលមានលិខិតអនុញ្ញាតឱ្យធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ចូលកំពង់ផែនេសាទដែលបានកំណត់ ដោយមិនបានជូនដំណឹងជាមុន២៤(ម្ភៃបួន)ម៉ោង ដល់អង្គភាពជំនាញទទួលបន្ទុកជលផល ឬមិនបានបង្ហាញលិខិតអនុញ្ញាតឱ្យនាវាចូលកំពង់ផែនេសាទដល់មន្ត្រីអធិការកិច្ចជលផល នៅពេលនាវាមកដល់។

១២- ប្រើនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទដែលបានអនុញ្ញាតឱ្យចូលចតចាកចេញពីកំពង់ផែនេសាទកម្ពុជា ដោយមិនបានជូនដំណឹងមុន១២(ដប់ពីរ)ម៉ោង មកអង្គភាពជំនាញទទួលបន្ទុកជលផល។

១៣- ប្រតិបត្តិករនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទ ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដែលបានកំណត់ ដោយគ្មានអ្នកសង្កេតការណ៍លើនាវា ឬមិនអនុវត្តតាមមុខងារនិងលក្ខខណ្ឌតម្រូវសម្រាប់អ្នកសង្កេតការណ៍។

១៤- ផ្ទេរផល ផលិតផលជលផលដោយប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យម ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ក្នុងកំពង់ផែនេសាទ ឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១៥- ប្រើសារធាតុបន្ថែមលើផល ផលិតផលជលផលនិងផលិតកម្មវារីវប្បកម្មលើសកម្រិតអនុញ្ញាត។

១៦- ប្រើកូនត្រីឬកូនវារីសត្វផ្សេងទៀតដែលបានពីការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ ដើម្បីផលិតជាម្សៅត្រី ខ្លាញ់ត្រី ឬចំណីវារីសត្វក្នុងការធ្វើវារីវប្បកម្មលើសពី១ ០០០(មួយពាន់)គីឡូក្រាម។

១៧- ផលិត នាំចូល នាំចេញ នាំឆ្លងកាត់ ធ្វើសន្និធិ វេចខ្ចប់ជាថ្មី ឬផ្គត់ផ្គង់ ចែកចាយ ឬលក់ដុំ លក់រាយ ចំណីវារីសត្វឬឱសថវារីសត្វ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១៨- ផលិតឬនាំចូលប្រភេទចំណីវារីសត្វឬឱសថវារីសត្វ សម្រាប់ផ្គត់ផ្គង់ ចែកចាយ ឬលក់ដុំ លក់រាយ ដែលមិនបានចុះបញ្ជី។

១៩- ប្រមូលផល ទិញ លក់ ធ្វើអំណោយ ឬចែកចាយនូវផល ផលិតផលវារីវប្បកម្មដែលមានជាតិពុលឬមានផ្ទុកសំណល់គីមីលើសកម្រិតកំណត់។

២០- ប្រមូលផល ទិញ លក់ ធ្វើអំណោយ ឬចែកចាយនូវផល ផលិតផលជលផល ដែលផ្ទុកសំណល់គីមីលើសកម្រិតកំណត់។

២១- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រំ កូនលៀស កូនខ្យង កូនខ្ចៅ ឬកូនឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ លើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២២-ធ្វើអាជីវកម្មផល ផលិតផលជលផលលើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២៣-ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលចាប់ពី៥០០(ប្រាំរយ)គីឡូក្រាម ដល់២ ០០០(ពីរពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

២៤- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់ ៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២៥- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដល់១០ ០០០(ដប់ពាន់)គីឡូក្រាម។

២៦- នាំចេញឬនាំឆ្លងកាត់ផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ចំពោះផល ផលិតផលជលផលដែលកំណត់ក្នុងបញ្ជីទំនិញហាមឃាត់ឬទំនិញជាប់កម្រិតកំណត់។

វត្ថុចាប់យកក្នុងចំណុច៣ ចំណុច៥ ចំណុច៦ ចំណុច៧ ចំណុច៨ ចំណុច៩ ចំណុច១០ ចំណុច១១ ចំណុច១២ ចំណុច១៣ ចំណុច១៤ ចំណុច១៦ ចំណុច១៧ ចំណុច១៨ ចំណុច២២ ចំណុច២៣ ចំណុច២៤

ចំណុច២៥ និងចំណុច២៦ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ ចំណុច៤ ចំណុច១៥ ចំណុច១៩ និងចំណុច២០ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច២១នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា១០ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទខ្នាតធំក្នុងកន្លែងការពារសត្វផ្សោតទន្លេមេគង្គ។

២- ការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនអូសគូ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៣- ធ្វើការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដោយអួនទិត អួនកាកឹម ឬអួនហ៊ុមរួមផ្សំភ្លើងប្រវែងស្របតាមការកំណត់ក្នុងឧបសម្ព័ន្ធទី២ ដោយក្រឡាខុសពីការកំណត់ក្នុងឧបសម្ព័ន្ធទី២ នៅចំណុចឧបករណ៍នេសាទសមុទ្រខ្នាតធំ នៃច្បាប់ស្តីពីជលផល។

៤- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រុំ កូនលៀស កូនខ្យង កូនខ្ចៅ ឬកូនឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ លើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដល់១០ ០០០(ដប់ពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៥- ធ្វើអាជីវកម្មផល ផលិតផលជលផលលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៦- ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលលើសពី២ ០០០(ពីរពាន់)គីឡូក្រាម ដល់៥ ០០០(ប្រាំពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

៧- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម ដោយគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផលលើសពី១០ ០០០(ដប់ពាន់)គីឡូក្រាម។

៨- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដល់១០ ០០០(ដប់ពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៩- ចាក់ចោល បោះចោល បង្ហូរ ឬបាចពង្រាយទៅក្នុងតំបន់គ្រប់គ្រងជលផល នូវកាកសំណល់រឹងឬរាវ ឬសារធាតុពុលដែលជះឥទ្ធិពលអវិជ្ជមានដល់វារីសត្វឬវារីរុក្ខជាតិ ដែលនាំឱ្យមានការបំពុលក្នុងតំបន់គ្រប់គ្រងជលផល។

វត្ថុចាប់យកក្នុងចំណុច២ ចំណុច៥ ចំណុច៦ ចំណុច៧ និងចំណុច៨ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច៣ និងចំណុច៩ នៃមាត្រានេះ ត្រូវរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋឬបំផ្លាញចោល ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច៤នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា១១ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬមិនអនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់។

២- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតធំ មិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការធ្វើរបាយការណ៍អំពីផលនេសាទ ឧបករណ៍នេសាទ ទីតាំងនាវា តំបន់ធ្វើនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

៣- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតធំ មិនរាយការណ៍អំពីទីតាំងប្រតិបត្តិការនៃការធ្វើនេសាទ ទិញ និងលក់ផលនេសាទ។

៤- ចាប់ ទិញ លក់ ធ្វើសន្និធិ ឬដឹកជញ្ជូនកូនត្រី កូនគ្រែង កូនគ្រុំ កូនលៀស កូនខ្យង កូនខ្ចៅ និងកូនឬពងវារីសត្វផ្សេងទៀតពីធម្មជាតិ លើសពី១០ ០០០(ដប់ពាន់)គីឡូក្រាម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

៥- នាំចូលនាវាខ្នាតធំសម្រាប់ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ ដោយគ្មានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

៦- ឡើងឬផ្ទេរផល ផលិតផលជលផលនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតមធ្យមឬខ្នាតធំ មិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការប្រើកំពង់ផែនេសាទ។

៧- ឡើងផល ផលិតផលជលផល ដោយប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមបរទេសក្នុងកំពង់ផែនេសាទឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា បន្ទាប់ពីបានឡើងផល ផលិតផលជលផលមិនធ្វើប្រតិវេទន៍អំពីការឡើងផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

៨- ផ្ទេរផល ផលិតផលជលផល ដោយប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមបរទេសក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ក្នុងកំពង់ផែនេសាទ ឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា បន្ទាប់ពីបានផ្ទេរផល ផលិតផលជលផល មិនធ្វើប្រតិវេទន៍អំពីការឡើងផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

៩- ផ្ទេរផល ផលិតផលជលផលដោយប្រើនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតធំក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ក្នុងកំពង់ផែនេសាទ ឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១០- ឡើង វេចខ្ចប់ កែច្នៃផលនេសាទ ឬប្រើសេវាកម្មផ្សេងៗនៅកំពង់ផែកម្ពុជា ដោយប្រើនាវានេសាទបរទេស ខុសពីកំពង់ផែនេសាទដែលបានកំណត់ឬមិនគោរពតាមលក្ខខណ្ឌតម្រូវ។

១១- ផ្ទេរផល ផលិតផលជលផលដោយប្រើនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យមក្នុងតំបន់ក្រៅដែនយុត្តាធិការឬកំពង់ផែនេសាទបរទេស ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

១២- ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលលើសពី៥ ០០០(ប្រាំពាន់)គីឡូក្រាម ដល់១០ ០០០(ដប់ពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានបញ្ញត្តិ។

១៣- នាំចូលផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មលើសពី១០ ០០០(ដប់ពាន់)គីឡូក្រាមដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ ចំណុច៣ ចំណុច៥ ចំណុច៦ ចំណុច៧ ចំណុច៨ ចំណុច៩ ចំណុច១០ ចំណុច១១ ចំណុច១២ និងចំណុច១៣ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច៤នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា១២ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០០ ០០០ ០០០(មួយរយលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជាដោយនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទខ្នាតមធ្យម ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬខុសពីកន្លែងនេសាទដែលបានកំណត់។

២- ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលលើសពី១០ ០០០(ដប់ពាន់)គីឡូក្រាម ដល់១០០ ០០០(មួយរយពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានបញ្ញត្តិ។

៣- ឡើងផល ផលិតផលជលផល ដោយប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតធំបរទេសក្នុងកំពង់ផែនេសាទឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា បន្ទាប់ពីបានឡើងផល ផលិតផលជលផលមិនធ្វើប្រតិវេទន៍អំពីការឡើងផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

៤- ផ្ទេរផល ផលិតផលជលផល ដោយប្រតិបត្តិករនាវានេសាទឬនាវាពាក់ព័ន្ធនឹងការនេសាទខ្នាតធំបរទេសក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ក្នុងកំពង់ផែនេសាទ ឬកន្លែងឡើងផល ផលិតផលជលផលកម្ពុជា បន្ទាប់ពីបានផ្ទេរផល ផលិតផលជលផល មិនធ្វើប្រតិវេទន៍អំពីការឡើងផល ផលិតផលជលផល ជូនអង្គភាពជំនាញទទួលបន្ទុកជលផល។

៥- ផ្ទេរផល ផលិតផលជលផលពីនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទនៅសមុទ្រអន្តរជាតិដែលស្ថិតក្រោមការគ្រប់គ្រងនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ មិនអនុលោមតាមលក្ខខណ្ឌនៃការផ្ទេរដែលកំណត់ដោយអង្គការថ្នាក់តំបន់នោះ។

៦- ឡើង វេចខ្ចប់ ឬកែច្នៃផល ផលិតផលជលផល ឬប្រើសេវាផ្សេងៗ ដោយប្រើនាវាសញ្ជាតិខ្មែរនៅកំពង់ផែនេសាទនៃរដ្ឋដទៃ ដែលទទួលស្គាល់ដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ក្នុងករណីអនុវត្តផ្ទុយនឹងលិខិតូបករណ៍ថ្នាក់តំបន់ឬអន្តរជាតិពាក់ព័ន្ធនឹងវិធានការរដ្ឋម្ចាស់កំពង់ផែនេសាទ។

៧- ផ្ទេរផល ផលិតផលជលផល ដោយប្រើនាវានេសាទសញ្ជាតិខ្មែរឬនាវាសញ្ជាតិខ្មែរពាក់ព័ន្ធនឹងការនេសាទខ្នាតធំក្នុងតំបន់ក្រៅដែនយុត្តាធិការឬក្នុងកំពង់ផែនេសាទបរទេស ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ ចំណុច៣ ចំណុច៤ ចំណុច៥ ចំណុច៦ និងចំណុច៧ នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា១៣ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២០០ ០០០ ០០០(ពីររយលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រកម្ពុជា ដោយប្រើនាវានេសាទបរទេសឬនាវាបរទេសពាក់ព័ន្ធនឹងការនេសាទខ្នាតធំ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬខុសពីកន្លែងនេសាទដែលបានកំណត់។

២- ធ្វើការនេសាទឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទនៅក្រៅដែនយុត្តាធិការជាតិ ដោយប្រើនាវាសញ្ជាតិខ្មែរខ្នាតធំ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬមិនអនុវត្តតាមវិធានការគ្រប់គ្រងនិងអភិរក្សនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់។

៣- ដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ផល ផលិតផលជលផលលើសពី១០០ ០០០(មួយរយពាន់)គីឡូក្រាម ដែលបានពីការធ្វើការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានបញ្ញត្តិ។

វត្ថុចាប់យកក្នុងចំណុច១ ចំណុច២ និងចំណុច៣នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា១៤ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃទីផ្សារនៃផលនេសាទនិងឧបករណ៍នេសាទ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ធ្វើការនេសាទដោយរបៀបនេសាទបែបថ្មីដែលបំផ្លាញធនធានជលផលឬប្រព័ន្ធអេកូឡូស៊ីជលផល។

២- ធ្វើការនេសាទដោយប្រើឧបករណ៍នេសាទបង្កើតថ្មីឬឧបករណ៍នេសាទដែលគ្មានក្នុងឧបសម្ព័ន្ធទី២ នៃច្បាប់ស្តីពីជលផល ឬគ្មានក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វត្ថុចាប់យកក្នុងចំណុច១នៃមាត្រានេះ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

វត្ថុចាប់យកក្នុងចំណុច២នៃមាត្រានេះ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

**មាត្រា១៥ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃមូលដ្ឋានដែលបានកំណត់នៃប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ឬប្រភេទវារីសត្វមានតម្លៃខ្ពស់ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសណាមួយដូចខាងក្រោម៖

១- ចាប់ ទិញ លក់ ប្រមូលផល កែច្នៃ ធ្វើសន្និធិ ឬដឹកជញ្ជូន នាំចេញ នាំចូល ឬនាំឆ្លងកាត់ នូវប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ឬប្រភេទដែលស្ថិតក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត។

២- នាំចេញ នាំចូល ឬនាំឆ្លងកាត់ នូវប្រភេទវារីសត្វដែលមានតម្លៃខ្ពស់ ដោយគ្មានលិខិតអនុញ្ញាតឬខុសលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬគ្មានវិញ្ញាបនបត្រសុខភាព ឬគ្មានវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ឬខុសលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងនិងត្រួតពិនិត្យលើគុណភាពនិងសុវត្ថិភាព។

តម្លៃមូលដ្ឋាននៃប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ឬប្រភេទវារីសត្វមានតម្លៃខ្ពស់ ត្រូវកំណត់តាមប្រភេទដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។ ក្នុងករណីចាំបាច់ ឧបសម្ព័ន្ធទី២ស្តីពីតម្លៃមូលដ្ឋាននៃប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ឬប្រភេទវារីសត្វមានតម្លៃខ្ពស់ អាចត្រូវបានកែសម្រួលដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

វត្ថុចាប់យកក្នុងចំណុច១ ត្រូវអនុវត្តស្របតាមមាត្រា៩០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីជលផល។

វត្ថុចាប់យកក្នុងចំណុច២ ត្រូវប្រគល់ឱ្យសាមីជនវិញ ក្រោយពីបានបង់ប្រាក់ពិន័យអន្តរការណ៍ ឬរឹបអូសមកជាទ្រព្យសម្បត្តិរដ្ឋក្នុងករណីជនល្មើសជាអញ្ញាតជន ដោយអនុវត្តស្របតាមច្បាប់ស្តីពីជលផល ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ដែលមានការពាក់ព័ន្ធជាធរមានផ្សេងទៀត។

**មាត្រា១៦ .-**

អំពើល្មើសដែលមានចែងក្នុងមាត្រា៦ ចំណុច១១ ចំណុច១២ ចំណុច១៣ ចំណុច១៤ ចំណុច១៥ ចំណុច១៦ ចំណុច១៧ ចំណុច១៨ ចំណុច១៩ ចំណុច២០ និងចំណុច២១ និងមាត្រា៨ ចំណុច៦ និងមាត្រា១០ ចំណុច៣ ដែលបានប្រព្រឹត្តក្នុងកន្លែងអភិរក្សជលផលឬកន្លែងអភិរក្សសត្វផ្សោតទន្លេមេគង្គ ត្រូវចាត់ទុកជាការនេសាទខ្នាតមធ្យម។

**មាត្រា១៧ .-**

ក្នុងករណីចាំបាច់ ប្រភេទឧបករណ៍នេសាទសម្រាប់ការធ្វើនេសាទខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃច្បាប់ស្តីពីជលផល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២៥/០២៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ ត្រូវបានកែសម្រួលឬកំណត់បន្ថែមដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បទប្បញ្ញត្តិក្នុងអនុក្រឹត្យនេះដែលពាក់ព័ន្ធខ្លឹមសារនៃការកែសម្រួលឬកំណត់បន្ថែមត្រូវមានអានុភាពអនុវត្ត។

## ជំពូកទី៣
## ការមិនរាងចាលឬការមិនបង់ប្រាក់ពិន័យអន្តរការណ៍

**មាត្រា១៨ .-**

ក្នុងករណីបុគ្គលដែលត្រូវបានពិន័យអន្តរការណ៍ម្តងហើយ នៅតែមិនរាងចាលបន្តប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងអនុក្រឹត្យនេះក្នុងរយៈពេលមិនលើសពី១(មួយ)ឆ្នាំ នៃការប្រព្រឹត្តល្មើសចុងក្រោយ ត្រូវពិន័យអន្តរការណ៍គុណនឹងទ្វេដងនៃប្រាក់ពិន័យចំពោះអំពើល្មើសលើកចុងក្រោយ ឬត្រូវគុណនឹងទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ ចំពោះអំពើល្មើសដែលមានចំនួនប្រាក់ពិន័យអន្តរការណ៍ច្រើនជាងមុន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

ការពិន័យអន្តរការណ៍ដែលកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តក្រោយរយៈពេល៣(បី)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២៦
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឌិត ទីណា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៦ ស្ដីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្ដីពីជលផល




| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 447906 | 1388483 | 51 | 406369 | 1403465 | 101 | 373578 | 1427063 | 151 | 373479 | 1463279 |
| 2 | 447196 | 1384731 | 52 | 405863 | 1401891 | 102 | 371377 | 1425979 | 152 | 374840 | 1462368 |
| 3 | 449864 | 1383441 | 53 | 406142 | 1403374 | 103 | 371458 | 1426361 | 153 | 377578 | 1462489 |
| 4 | 452827 | 1381878 | 54 | 404947 | 1402982 | 104 | 370749 | 1426280 | 154 | 379412 | 1461434 |
| 5 | 456220 | 1380185 | 55 | 405836 | 1405580 | 105 | 369353 | 1427941 | 155 | 381007 | 1461383 |
| 6 | 456682 | 1378449 | 56 | 406138 | 1407124 | 106 | 369220 | 1429953 | 156 | 382072 | 1460541 |
| 7 | 455053 | 1376290 | 57 | 404932 | 1406120 | 107 | 369423 | 1430787 | 157 | 383157 | 1460809 |
| 8 | 452763 | 1378217 | 58 | 404410 | 1408196 | 108 | 368846 | 1430958 | 158 | 384313 | 1460287 |
| 9 | 450809 | 1379573 | 59 | 404268 | 1411170 | 109 | 368550 | 1432199 | 159 | 385734 | 1460338 |
| 10 | 448220 | 1380820 | 60 | 404972 | 1412851 | 110 | 369610 | 1432556 | 160 | 387235 | 1459639 |
| 11 | 449548 | 1378954 | 61 | 404255 | 1413498 | 111 | 369381 | 1434222 | 161 | 388879 | 1458868 |
| 12 | 451692 | 1377168 | 62 | 403900 | 1413348 | 112 | 368776 | 1435310 | 162 | 390391 | 1458590 |
| 13 | 453759 | 1375739 | 63 | 404182 | 1412169 | 113 | 367498 | 1435928 | 163 | 394413 | 1455849 |
| 14 | 454770 | 1374252 | 64 | 403842 | 1411893 | 114 | 365799 | 1437398 | 164 | 396789 | 1453122 |
| 15 | 454707 | 1372173 | 65 | 403690 | 1413418 | 115 | 364451 | 1438474 | 165 | 399349 | 1449581 |
| 16 | 453731 | 1373322 | 66 | 402034 | 1413070 | 116 | 366893 | 1438953 | 166 | 400454 | 1447654 |
| 17 | 450707 | 1375015 | 67 | 402282 | 1415021 | 117 | 367226 | 1440238 | 167 | 401538 | 1445574 |
| 18 | 447735 | 1377009 | 68 | 400112 | 1414697 | 118 | 366352 | 1440791 | 168 | 402802 | 1442941 |
| 19 | 446597 | 1379452 | 69 | 398938 | 1413111 | 119 | 364417 | 1441596 | 169 | 403386 | 1440709 |
| 20 | 445579 | 1381902 | 70 | 398461 | 1414591 | 120 | 363255 | 1442825 | 170 | 404235 | 1437794 |
| 21 | 443982 | 1382471 | 71 | 397775 | 1413227 | 121 | 363795 | 1442921 | 171 | 404763 | 1435802 |
| 22 | 440331 | 1382644 | 72 | 395550 | 1413905 | 122 | 362632 | 1443903 | 172 | 405189 | 1434027 |
| 23 | 435904 | 1382681 | 73 | 393633 | 1412953 | 123 | 362789 | 1443366 | 173 | 405956 | 1432290 |
| 24 | 432874 | 1382619 | 74 | 392081 | 1416396 | 124 | 361430 | 1445159 | 174 | 407773 | 1431387 |
| 25 | 429671 | 1383675 | 75 | 391446 | 1414310 | 125 | 360343 | 1446853 | 175 | 409108 | 1428118 |
| 26 | 426757 | 1385485 | 76 | 391443 | 1415072 | 126 | 359900 | 1449101 | 176 | 408353 | 1425839 |
| 27 | 424177 | 1387913 | 77 | 390739 | 1414635 | 127 | 360349 | 1449045 | 177 | 409086 | 1422941 |
| 28 | 423671 | 1387176 | 78 | 390430 | 1414883 | 128 | 360069 | 1451824 | 178 | 412180 | 1418158 |
| 29 | 422761 | 1388533 | 79 | 389127 | 1415279 | 129 | 359784 | 1453322 | 179 | 414642 | 1413094 |
| 30 | 421698 | 1387905 | 80 | 388229 | 1415813 | 130 | 359699 | 1455457 | 180 | 416112 | 1408686 |
| 31 | 419780 | 1388297 | 81 | 387230 | 1416396 | 131 | 359919 | 1456164 | 181 | 425506 | 1407453 |
| 32 | 417096 | 1389895 | 82 | 386992 | 1418175 | 132 | 359482 | 1457822 | 182 | 438028 | 1410280 |
| 33 | 414431 | 1389895 | 83 | 386684 | 1419698 | 133 | 359212 | 1458940 | 183 | 440557 | 1408504 |
| 34 | 412725 | 1391576 | 84 | 386319 | 1418303 | 134 | 358612 | 1460321 | 184 | 443417 | 1400757 |
| 35 | 412070 | 1393444 | 85 | 385173 | 1417715 | 135 | 358684 | 1460622 | 185 | 442429 | 1395315 |
| 36 | 411284 | 1392099 | 86 | 384498 | 1417421 | 136 | 357914 | 1461158 | 186 | 440241 | 1392512 |
| 37 | 411827 | 1393658 | 87 | 384302 | 1417818 | 137 | 358155 | 1463098 | 187 | 442291 | 1391298 |
| 38 | 410708 | 1395806 | 88 | 384211 | 1418831 | 138 | 359060 | 1464992 | 188 | 444720 | 1388399 |
| 39 | 410039 | 1397464 | 89 | 383973 | 1420049 | 139 | 360217 | 1465813 | 189 | 442453 | 1386470 |
| 40 | 409420 | 1397009 | 90 | 383515 | 1420103 | 140 | 360256 | 1466961 | 190 | 440134 | 1386904 |
| 41 | 408374 | 1398135 | 91 | 382460 | 1419251 | 141 | 361462 | 1465289 | 191 | 436527 | 1388809 |
| 42 | 407422 | 1399141 | 92 | 382031 | 1420334 | 142 | 361361 | 1466633 | 192 | 435410 | 1387817 |
| 43 | 407680 | 1399449 | 93 | 381238 | 1420367 | 143 | 363118 | 1466095 | 193 | 438540 | 1385294 |
| 44 | 408662 | 1399154 | 94 | 381037 | 1422317 | 144 | 364413 | 1465522 | 194 | 440652 | 1384585 |
| 45 | 408144 | 1400710 | 95 | 378572 | 1422476 | 145 | 365696 | 1465097 | 195 | 443278 | 1385472 |
| 46 | 408649 | 1402025 | 96 | 378247 | 1424298 | 146 | 367466 | 1464528 | 196 | 445512 | 1386151 |
| 47 | 408745 | 1403139 | 97 | 377808 | 1423864 | 147 | 368072 | 1464018 | 197 | 446253 | 1385307 |
| 48 | 408296 | 1403388 | 98 | 377083 | 1425768 | 148 | 368913 | 1464142 | 198 | 444678 | 1385011 |
| 49 | 408243 | 1402564 | 99 | 375372 | 1426021 | 149 | 370094 | 1464129 | 199 | 446250 | 1383908 |
| 50 | 407471 | 1403507 | 100 | 373885 | 1427749 | 150 | 371347 | 1463335 | 200 | 447137 | 1386285 |

ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០២៦
ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីជលផល

# តម្លៃមូលដ្ឋាននៃប្រភេទវារីសត្វកំពុងរងគ្រោះថ្នាក់ឬប្រភេទវារីសត្វមានតម្លៃខ្ពស់

## ក- ប្រភេទវារីសត្វទឹកសាប

| ល.រ. | ឈ្មោះប្រភេទវារីសត្វ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | តម្លៃមេវារីសត្វ (រៀល/ក្បាល) | តម្លៃកូនវារីសត្វ (រៀល/ក្បាល) |
|---|---|---|---|---|---|
| ១ | ផ្សោតក្បាលត្រឡោក  | *Orcaella brevirostris* | Irrawaddy dolphin | ៥ 000 000 | ៥ 000 000 |
| ២ | ត្រីគល់រាំង  | *Catlocarpio siamensis* | Giant barb | ១ 000 000 | ១0 000 |
| ៣ | ត្រីរាជ  | *Pangasianodon gigas* | Mekong giant catfish | ១ 000 000 | ២0 000 |
| ៤ | ត្រីប៉ាសាណាក់  | *Aaptosyax grypus* | Giant salmon carp | ៥00 000 | ២0 000 |
| ៥ | ត្រីនាគឬត្រីតាពត  | *Scleropages formosus* | Asian bonytongue | ៥00 000 | ២0 000 |
| ៦ | ត្រីត្រសក់ក្រហម  | *Probarbus jullieni* | Isok barb | ២00 000 | ១0 000 |
| ៧ | ត្រីបីកំណាត់ឬត្រីខ្លា  | *Puntius partipentazona* | Tiger barb | ៥0 000 | ៥000 |

| | | | | | |
|---|---|---|---|---|---|
| ៨ | ត្រីកៀតស្រង់<br> | *Balantiocheilos melanopterus* | Bala sharkminnow | ៥០ ០០០ | ៥០០០ |
| ៩ | ត្រីគជ្រា<br> | *Puntioplites bulu* | Bulu barb | ៥០ ០០០ | ៥០០០ |
| ១០ | ត្រីត្រចៀកដំរីឮ<br> | *Osphronemus exodon* | Elephant ear gourami | ៥០ ០០០ | ៥០០០ |
| ១១ | ត្រីរមាស<br> | *Osphronemus goramy* | Giant gourami | ៥០ ០០០ | ៥០០០ |
| ១២ | ត្រីកន្ត្រប់ខ្លា<br> | *Datnioides undecimradiatus* | Narrow barred tigerperch | ២០០ ០០០ | ២០ ០០០ |
| ១៣ | ត្រីស្ទូក<br> | *Wallago leeri* | Striped Wallago Catfish | ៥០០ ០០០ | ៥០ ០០០ |
| ១៤ | ត្រីត្រសក់<br> | *Probarbus labeamajor* | Thicklip barb | ៤០ ០០០ | ១០ ០០០ |
| ១៥ | ត្រីត្រសក់ស<br> | *Probarbus labeaminor* | Thinlip barb | ៤០ ០០០ | ១០ ០០០ |
| ១៦ | ត្រីធ្មាក្រពើ<br> | *Lycothrissa crocodilus* | Sabertooth thryssa | ១០ ០០០ | ៥០០០ |

| | | | | | |
|---|---|---|---|---|---|
| ១៧ | ត្រីឆ្លុក  | *Anguilla marmorata* | Giant mottled eel | ១ 000 000 | ១ 000 000 |
| ១៨ | ត្រីថ្ករ  | *Pristis microdon* | Sawfish | ៥ 000 000 | ៥ 000 000 |
| ១៩ | បបែលយក្ស  | *Urogymnus Polylepis* | Giant freshwater stingray | ៥ 000 000 | ១ 000 000 |
| ២០ | បបែលភ្លើង  | *Hemitrygon laosensis* | Mekong stingray | ១ 000 000 | ៥00 000 |
| ២១ | ក្រពើត្រី  | *Crocodylus siamensis* | Siamese crocodile | ២ 000 000 | ៥0 000 |
| ២២ | អណ្ដើកហ្លួងឬអណ្ដើកសរសៃ  | *Batagur affinis* | Mangrove terrapin or estuarine terrapin | ១ 000 000 | ៥00 000 |
| ២៣ | អណ្ដើកក្បាលធំឬអណ្ដើកចំពុះសេក  | *Platysternon megacephalum* | Big-headed Turtle | ១ 000 000 | ៥00 000 |
| ២៤ | អណ្ដើកសោម  | *Heosemys grandis* | Asian giant terrapin | ១ 000 000 | ៥00 000 |
| ២៥ | អណ្ដើកក្អែក  | *Siebenrockiella crassicollis* | Black marsh turtle | ១ 000 000 | ១00 000 |

| | | | | | |
|---|---|---|---|---|---|
| ២៦ | អណ្តើកបិទមុខ  | *Coura amboinonsis* | Asian box turtle | ១ ០០០ ០០០ | ១០០ ០០០ |
| ២៧ | កន្ធាយអាស៊ី  | *Amyda cartilaginea* | Asiatic soft – shell turtle | ១ ០០០ ០០០ | ២០០ ០០០ |
| ២៨ | អណ្តើកស្រែឆ្នូតក្បាលលឿង  | *Malayanmys subtrijuga* | Mekong Snail eating turtle | ១ ០០០ ០០០ | ១០០ ០០០ |
| ២៩ | អណ្តើកស្រែទ្រូងខ្មៅ  | *Malayanmys kharotensiss* | Khorat snail-eating turtle | ៣០០ ០០០ | ៥០ ០០០ |
| ៣០ | អណ្តើកស្រែឆ្នូតក្បាលប្រផេះ  | *Malayanmys macrocephalic* | Malayan snail eating turtle | ៣០០ ០០០ | ៥០ ០០០ |
| ៣១ | អណ្តើកទ្រូងខ្មៅ  | *Cyclemys oldhamii spp.* | Oldham's leaf turtle | ៣០០ ០០០ | ៥០ ០០០ |
| ៣២ | អណ្តើកស្នូកឆ្នូត  | *Cyclemys pulchristriata spp.* | Eastern black-bridged leaf turtle | ៣០០ ០០០ | ៥០ ០០០ |
| ៣៣ | អណ្តើកក្រវាញ  | *Cyclemys atripons spp.* | Western black-bridged leaf turtle | ៣០០ ០០០ | ៥០ ០០០ |
| ៣៤ | អណ្តើកសង្កល់  | *Heosemys annandalii* | Yellow-headed temple turtle | ៣០០ ០០០ | |

| | | | | | |
|---|---|---|---|---|---|
| ៣៥ | កន្ទាយក្បាលកង្កែប  | *Pelochelys cantorii* | Asian giant soft-shell turtle | ៣០០ ០០០ | ៥០ ០០០ |

## ខ- ប្រភេទវារីសត្វសមុទ្រ

| | | | | | |
|---|---|---|---|---|---|
| ១ | ផ្សោតក្បាលត្រឡោក  | *Orcaella brevirostris* | Irrawaddy dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ២ | ផ្សោតច្រមុះដបចំពុះវែង  | *Tursiops truncatus* | Common bottlenose dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៣ | ផ្សោតឃ្លៀចឬផ្កាឈូក  | *Sousa chinensis* | Indo-Pacific hump-backed dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៤ | ផ្សោតធ្នូតភ្នែក  | *Stenella longirostris roseinventris* | Dwarf spinner dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៥ | ផ្សោតអុច  | *Stenella attenuata* | Pantropical spotted dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៦ | ផ្សោតឥតព្រុយខ្នង  | *Neophocaena phocaenoides* | Finless porpoise | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៧ | ផ្សោតខ្មៅលឿង  | *Dolphinus capensis tropicalis* | Long-beaked common dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៨ | ផ្សោតច្រមុះខ្លី  | *Tursiops aduncus* | Indo-Pacific bottlenose dolphin | ៥ ០០០ ០០០ | ៣ ០០០ ០០០ |
| ៩ | ជ្រូកទឹក  | *Dugong dugon* | Dugong | ២០ ០០០ ០០០ | ១០ ០០០ ០០០ |

| | | | | | |
|---|---|---|---|---|---|
| ១០ | ត្រីបាណន់គីង្គក់  | *Rhincodon typus* | Whale shark | ២០ 000 000 | ១០ 000 000 |
| ១១ | បាឡែនក្របី  | *Pseudorca crassidens* | False killer whale | ១០ 000 000 | ៥ 000 000 |
| ១២ | បាឡែនក្បាលធំ  | *Globicephala macrorhynchus* | Short-finned pilot whale | ១០ 000 000 | ៥ 000 000 |
| ១៣ | ត្រីសេកបូក  | *Cheilinus undulates* | Humphead Wrasse | ៣00 000 | ៣0 000 |
| ១៤ | ត្រីបបែលខ្លែង  | *Mobula japanica (Mobula mobular)* | Spinetail mobula | ១ 000 000 | ៣00 000 |
| ១៥ | ត្រីបបែលអក  | *Aetobatus narinari* | Spotted eagle ray | ១ 000 000 | ៣00 000 |
| ១៦ | ប្រឡាំងកាស  | *Tachypleus gigas* | Traingular-tail horseshoe crab | ១0 000 | ៥000 |
| ១៧ | សេះសមុទ្រ  | *Hippocampus spp.* | Seahorse | ៥0 000 | ១0 000 |
| ១៨ | ល្មិច  | *Chelonia mydas* | Green turtle | ៣ 000 000 | [illegible] |

| | | | | | |
|---|---|---|---|---|---|
| ១៩ | ល្មិចព្រុយបីឬល្មិចស្តី  | *Dermochelys coriacea* | Leatherback turtle | ៣ 000 000 | ៥00 000 |
| ២០ | ល្មិចក្បាលធំ  | *Caretta caretta* | Loggerhead turtle | ៣ 000 000 | ៥00 000 |
| ២១ | ល្មិចប្រផេះ  | *Lepidochelys olivacea* | Olive ridley turtle | ៣ 000 000 | ៥00 000 |
| ២២ | ក្រាស  | *Eretmochelys imbricata* | Hawksbill turtle | ៣ 000 000 | ៥00 000 |
| ២៣ | ក្រពើសមុទ្រ  | *Crocodylus porosus* | Estuarine crocodile | ៥ 000 000 | ១ 000 000 |
| ២៤ | គ្រំយក្ស  | *Tridacna.spp* | Giant Clam | ១ 000 000 | ៥00 000 |
| ២៥ | ខ្យងកោផ្ទ  | *Trochus niloticus* | Commercial top | ១0 000 | ៥000 |
| ២៦ | ខ្យងគជ់ ឬ ខ្យងប្រាក់  | *Turbo marmoratus* | Green turbo or green snail | ១0 000 | ៥000 |
| ២៧ | បង្កងនាគ  | *Panulirus spp.* | Spiny Lobster | ២00 00[illegible] | |

| | | | | | |
|---|---|---|---|---|---|
| ២៨ | ផ្កាថ្ម  | *Anthozoa spp.* | Corals | ១០០ ០០០ | ១០០ ០០០ |
| ២៩ | ស្ពង់ស  | *Cliona spp.* | Neptune's cup sponge | ៥០ ០០០ | ៥០ ០០០ |